# របាយការណ៍ប្រចាំត្រីមាសទី២
# ឆ្នាំ ២០២៤

០១ មេសា - ៣០ មិថុនា ២០២៤

## អ អិម អេ (ខេមបូឌា) ម.ក

R M A (CAMBODIA) PLC.



ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក
ទីស្នាក់ការចុះបញ្ជីផ្ទះលេខ ២៧ ផ្លូវលេខ១៣៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទទំនាក់ទំនង: +៨៥៥ (0) ២៣-៨៨៨-000, ទូរស័ព្ទចល័ត: +៨៥៥ (0) ២៣-៨២៦-៧៥២
www.cambodia.rmagroup.net

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាពាន់រៀល) | ត្រីមាសទី២ ឆ្នាំ២០២៤ | ២០២៣ | ២០២២ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ៨៦៨.៨៩០.៧៣១ | ១.០៩៣.៥១១.៧១០ | ៨៨៩.២៩៥.២៣២ |
| បំណុលសរុប | ៣៥៤.០៧០.៨៧៧ | ៥៨៦.៦០៩.៧៤៦ | ៤៥១.៣៩២.៤៣៣ |
| មូលធនក្រុមហ៊ុនសរុប | ៥១៤.៨១៩.៨៥៤ | ៥០៦.៩០១.៩៦៤ | ៤៣៧.៩០២.៧៩៩ |

| ប្រាក់ចំណេញ/(ខាត) (គិតជាពាន់រៀល) | ត្រីមាសទី២ ឆ្នាំ២០២៤ | ត្រីមាសទី២ ឆ្នាំ២០២៣ | ត្រីមាសទី២ ឆ្នាំ២០២២ |
|---|---|---|---|
| ចំណូលសរុប | ៤៤១.៣២៥.៩២១ | ៤៨៧.០៧០.៦១៥ | ៣២១.៧៧៩.៧១៨ |
| ប្រាក់ចំណេញដុល | ៦២.០៥៦.០២៤ | ៨៩.០៥៨.៩៦៧ | ៦១.៣៣៦.៦៩០ |
| ប្រាក់ចំណេញពីកិច្ចប្រតិបត្តិការ | ៣១.៣១៣.៨៦៩ | ៥៥.៩៤៣.៩៨៤ | ៤៤.០១១.៣៨០ |
| បន្ទុកហិរញ្ញប្បទាន | ៥.៦០៣.៥៤៥ | ៦.៦៤៤.១៥៥ | ២.១០៨.៤៩៥ |
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ | ២៥.៧១០.៣២៤ | ៤៩.២៩៩.៨២៩ | ៤១.៩០២.៨៨៥ |
| ប្រាក់ចំណេញ (ខាត) ក្រោយបង់ពន្ធ | ២០.៤៣៨.៥០៣ | ៤៣.៦០៣.៤៦៨ | ៣៤.៧២៣.៨០៦ |
| លទ្ធផលចំណេញលម្អិតក្នុងគ្រា | ២៩.០៤៥.៤៤៥ | ៥២.៩៥៤.៣៩៦ | ៣៦.៤៤១.៩៧៦ |

| អនុបាតហិរញ្ញវត្ថុ | ត្រីមាសទី២ ឆ្នាំ២០២៤ | ២០២៣ | ២០២២ |
|---|---|---|---|
| អនុបាតសាធនភាព | ០,៧ | ១,២ | ១,០ |
| អនុបាតចរន្ត (Current Ratio) | ៤,៦ | ២,៥ | ២,០ |
| អនុបាតចរន្តលឿន (Quick Ratio) | ២,១ | ០,៦ | ០,៧ |

| អនុបាតចំណេញភាព | ត្រីមាសទី ២ ឆ្នាំ២០២៤ | ត្រីមាសទី ២ ឆ្នាំ២០២៣ | ត្រីមាសទី ២ ឆ្នាំ២០២២ |
|---|---|---|---|
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | ៣,០% | ៥,៥% | ៥,៧% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | ៥,៧% | ១០,៨% | ១១,៤% |
| គម្លាតចំណេញដុល (Gross Profit Margin) | ១៤,១% | ១៨,៣% | ១៩,១% |
| គម្លាតចំណេញ (Profit Margin) | ៦,៦% | ១០,៩% | ១១,៣% |
| អនុបាតលទ្ធភាពបង់ការប្រាក់ | ៥,៦ | ៨,៤ | ២០,៩ |

## ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប










ប្រាក់ចំណូល និង ចំណូលសុទ្ធ (គិតជាពាន់រៀល)
2,500,000,000
2,000,000,000
1,500,000,000
1,000,000,000
500,000,000
-
12.0%
10.0%
8.0%
6.0%
4.0%
2.0%
0.0%
១១,២%
២.២០៣.២៥៣.៨៥៣
១.៨០០.៣៦២.០៩៤
៦,១%
៥,១%
៨៧៣.៣២៥.០៦៣
២០២២
២០២៣
ខែមករា ដល់ ខែមិថុនា ឆ្នាំ ២០២៤
ប្រាក់ចំណូល
ចំណូលសុទ្ធ%

# សមាជិកក្រុមប្រឹក្សាភិបាល



លោក Christian Wiedmann | លោក ខន សាំង | លោក Kevin Whitcraft | លោក Tom Whitcraft | លោក Ith Vichit

លោក Kevin Whitcraft

ប្រធានក្រុមប្រឹក្សាភិបាល

លោក ខន សាំង

អភិបាលប្រតិបត្តិ

លោក Tom Whitcraft

អភិបាលមិនប្រតិបត្តិ

លោក Christian Wiedmann

អភិបាលមិនប្រតិបត្តិ

លោក Ith Vichit

អភិបាលឯករាជ្យ

## សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

វិនិយោគិនជាទីគោរព

ក្នុងរបាយការណ៍ប្រចាំត្រីមាសមុនៗ ខ្ញុំបាទបានជម្រាបជូនអំពីរបាយការណ៍សង្ខេបស្តីពីលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក (តទៅនេះហៅកាត់ថា "ក្រុមហ៊ុន RMAC") ស្របទៅតាមលក្ខខណ្ឌតម្រូវរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក)។

ដោយផ្អែកលើទស្សនៈសេដ្ឋកិច្ច អ្នកវិភាគសេដ្ឋកិច្ចបានយល់ស្របទៅលើកំណើនសេដ្ឋកិច្ច ៥,៨% របស់កម្ពុជានៅឆ្នាំ២០២៤។ នេះជាគំនិតដែលត្រូវបានលើកឡើងដោយធនាគារពិភពលោកកាលពីដើមខែមេសា។ សេដ្ឋកិច្ចកម្ពុជាមានកំណើនឡើងវិញនៅក្នុងឆមាសទី១ ផ្អែកលើតម្រូវការខ្ពស់នៃផលិតផលមកពីទីផ្សារអន្តរជាតិ។ អតិផរណាគឺត្រូវបានរក្សាក្នុងកម្រិតទាបមួយ។ ខណៈពេលដែលនៅមានភាពទន់ខ្សោយនៅឡើយ វិស័យសំណង់បានបង្ហាញឱ្យឃើញពីសញ្ញាណនៃការប្រែប្រួលបន្តិចបន្តួច។ ឥណទានក្នុងស្រុកមានការកើនឡើងតិចតួច ខណៈពេលដែលធនាគារមួយចំនួននៅតែប្រឈមមុខនឹងកម្ចីដែលមានបញ្ហា។ យើងបានកត់សម្គាល់ឃើញអំពីការរីកចម្រើនមួយចំនួនចំពោះវិស័យទេសចរណ៍ ប៉ុន្តែតួលេខនៃកំណើននេះ នៅមិនទាន់បំពេញចំពោះការខ្វះខាតចំណូលក្នុងវិស័យនេះនៅឡើយ។

តាមរយៈការរំពឹងទុកនៃទីផ្សាររថយន្ត កំណើននៃការលក់រថយន្តថ្មីបានកើនឡើងដល់ ៦,៦០០គ្រឿង នៅក្នុងត្រីមាសទី២ នៃឆ្នាំ២០២៤ បើធៀបទៅនឹងត្រីមាសទី១ នៃឆ្នាំ២០២៤។ ទោះយ៉ាងណាក៏ដោយ តួលេខនេះនៅតែមានការធ្លាក់ចុះរហូតដល់ -១០% នៅក្នុងត្រីមាសនៃឆ្នាំ២០២៤ បើធៀបទៅនឹងដំណាច់ត្រីមាសដូចគ្នានៃឆ្នាំ២០២៣។

ស្ថិតក្នុងស្ថានភាពនេះ RMAC សម្រេចបានកំណើននៃការលក់ដ៏ខ្ពស់នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៤ ដោយមានការកើនឡើង +១,៩% បើធៀបទៅនឹងត្រីមាសទី១ នៃឆ្នាំ២០២៤ ប៉ុន្តែធ្លាក់ចុះ -៨,៧% បើធៀបទៅនឹងត្រីមាសទី២ នៃឆ្នាំ២០២៣។ ក្រឡេកមកមើលការលក់នៅត្រីមាសនៃឆ្នាំ២០២៤ កំណត់ត្រាការលក់របស់ RMAC មានការធ្លាក់ចុះ -២២% បើធៀបទៅនឹងត្រីមាសដូចគ្នានៃឆ្នាំ២០២៣។

នៅក្នុងអំឡុងត្រីមាសទី២ នៃឆ្នាំ២០២៤ ក្រុមហ៊ុន RMAC យើងខ្ញុំបានដាក់សម្ពោធដោយជោគជ័យនូវរថយន្តស៊េរីថ្មីម៉ូដែល Ford Territory Dark Edition ដែលនឹងរំពឹងថានឹងទទួលបានការចាប់អារម្មណ៍ពីទីផ្សាររថយន្ត។ ផ្នែកលក់រថយន្ត ហ្វដ ខេមបូឌា បានវិនិយោគសាខាថ្មីលំដាប់ 3S នៅសង្កាត់ភ្នំពេញថ្មី ដែលបង្ហាញពីការប្តេជ្ញាចិត្តយូរអង្វែងនៃក្រុមហ៊ុនរបស់យើងនៅក្នុងប្រទេសកម្ពុជា។

សម្រាប់ការចូលរួមចំណែកក្នុងសកម្មភាពសង្គម RMAC ពិតជាមានសេចក្តីសោមនស្សរីករាយដោយបានចូលរួមក្នុងការបរិច្ចាគកង់ចំនួន ៥០គ្រឿង ជូនទៅរដ្ឋបាលស្រុកទឹកឈូ ខេត្តកំពត។

ក្នុងនាមខ្ញុំបាទតំណាងឱ្យក្រុមប្រឹក្សាភិបាលទាំងអស់ សូមថ្លែងអំណរគុណចំពោះអតិថិជនទាំងអស់នៅក្នុងប្រទេសកម្ពុជា ដែលតែងតែមានភក្តីភាព និងមានការចូលចិត្ត និងតែងតែគាំទ្រដល់ក្រុមហ៊ុនយើងខ្ញុំកន្លងមក។ យើងខ្ញុំសូមជូនពរដល់ប្រជាជនកម្ពុជាទាំងអស់ សូមមានសុខសុវត្ថិភាព និងសុខភាពល្អជានិច្ចនិរន្តន៍។

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អ អិម អេ (ខេមបូឌា) ម.ក
R M A (CAMBODIA) PLC.
KINGDOM OF CAMBODIA

លោក Kevin Whitcraft
ប្រធានក្រុមប្រឹក្សាភិបាល
កាលបរិច្ឆេទ៖ ២៨ សីហា ២០២៤

## មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ 3

ក្រាបស្ដីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប ........ 4

សមាជិកក្រុមប្រឹក្សាភិបាល ........ 6

សេចក្ដីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ 7

ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ ........ 99

ក .ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ ........ 9

ខ .សកម្មភាពអាជីវកម្ម ........ 9

គ .ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស ........ 10

ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ 11

ក .លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក ........ 11

ខ .រចនាសម្ព័ន្ធប្រាក់ចំណូល ........ 12

ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ ........ 13

ផ្នែកទី៤ .ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង ........ 14

ក.ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ 14

ខ.កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ ........ 15

គ. ការផ្លាស់ប្ដូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល ........ 15

ឃ. ផលប៉ះពាល់នៃអត្រាប្ដូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ ........ 15

ង. ផលប៉ះពាល់នៃអតិផរណា ........ 15

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ........ 15

ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ ........ 15

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ........ 16

## ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

### ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ

| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាខ្មែរ | អ អិម អេ (ខេមបូឌា) ម.ក |
|---|---|
| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាឡាតាំង | RMA (CAMBODIA) PLC |
| លេខកូដស្តង់ដារ | KH2000121A44 |
| អាសយដ្ឋាន | ផ្ទះលេខ ២៧ E1 ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០) ២៣ ៨៨៣ ៨៨៨ / ១២ ៨៦៧ ៦៩៧ |
| លេខទូរសារ | +៨៥៥ (០) ២៣ ៨២៦ ៧៥២ |
| គេហទំព័រ | www.cambodia.rmagroup.net |
| អ៊ីម៉ែល | saing.ngorn@rmagroup.net |
| លេខចុះបញ្ជីក្រុមហ៊ុន | ០០០០១១២១ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០២ |
| លេខចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ០៦៨/២០ គ.ម.ក សសរ SECC ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០ |
| ឈ្មោះអ្នកតំណាងរបស់ក្រុមហ៊ុនបោះផ្សាយ | លោក ងន សាំង |
| លេខាធិការក្រុមហ៊ុន | លោក មាស សុវណ្ណ (អ៊ីមែល៖ sovan.meas@rmagroup.net) |

### ខ. សកម្មភាពអាជីវកម្ម

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនចែកចាយរថយន្ត កសិកម្ម និងគ្រឿងបន្លាស់ធន់ធ្ងន់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាក្រុមហ៊ុនផ្តល់ការធានា និងសេវាកម្មក្រោយការលក់សម្រាប់ម៉ាកល្បីៗលំដាប់ពិភពលោករួមមានដូចជា Ford, TCM, JCB, FUSO, John Deere, Jaguar Land Rover, MS Pallet, Megger & Sebar, GenieGrips, Hako, PowerBoss, AJAX, Piaggio, Changan, Haulotte, សេវាកម្មក្រោយការលក់ Mercedes-Benz និង គ្រឿងបន្លាស់រថយន្ត (ថ្នាំលាបរថយន្ត និងអាគុយ)។

ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនផ្តល់សេវាកម្មនាំចូលរថយន្ត និង ផ្តល់ដំណោះស្រាយលើសេវាកម្មផ្សេងៗដែលទាក់ទងនឹងគ្រឿងផ្គត់ផ្គង់ និងសេវាថែទាំក្រោយការលក់។

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនមេរបស់ RMA Group ដែលមានទីស្នាក់ការកណ្តាលប្រតិបត្តិប្រចាំតំបន់នៅទីក្រុងបាងកក ប្រទេសថៃ។

## គ. ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស

ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសត្រូវបានកំណត់ដូចខាងក្រោម៖

### ខែ ឧសភា ឆ្នាំ២០២៤

**ការបើកសម្ពោធរថយន្ត FORD RANGER ស៊េរី ឆ្នាំ២០២៤**

កាលពីថ្ងៃទី២៤ ខែឧសភា ហ្វដ ខេមបូឌា បានដាក់បង្ហាញរថយន្ត Ford Ranger ស៊េរីឆ្នាំ២០២៤ នៅ ដឹ ព្រីមៀរ សែនសុខ ដោយមានភ្ញៀវចូលរួមចំនួន ១៥០០ នាក់។ ភាពលេចធ្លោរបស់ដំណើរការ នៃរថយន្ត Off-Road ត្រូវបានរំលេចឡើងជាពិសេស រួមជាមួយរូបរាង និងពណ៌ដ៏ទាក់ទាញ។



**ការបរិច្ចាគកង់របស់ អ ម អេ (ខេមបូឌា)**

កង់ចំនួន ៥០ គ្រឿងត្រូវបានប្រគល់ជូនរដ្ឋបាលស្រុកទឹកឈូ ខេត្តកំពត, ក្នុងនោះកង់ចំនួន ២៨ ត្រូវបានប្រគល់ជូនសិស្សានុសិស្សក្រីក្រ។



### ខែ មិថុនា ឆ្នាំ២០២៤

**ពិធីសម្ពោធរថយន្ត FORD TERRITORY DARK EDITION**

នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៤ ហ្វដ ខេមបូឌា បានសម្ពោធរថយន្ត Ford Territory Dark Edition ថ្មីទាំងអស់ នៅចំពោះមុខភ្ញៀវចំនួន ២៥០០ នាក់។ រថយន្តថ្មីនេះបានភ្ជាប់ជាមួយនឹងការរចនាថ្មី ជាមួយនឹងផ្នែកខាងក្នុងពណ៌ខ្មៅរលោង ដែលបានធ្វើឲ្យទស្សនិកជនមានការចាប់អារម្មណ៍។ យើងរំពឹងថានឹងមានភាពជោគជ័យផ្នែកពាណិជ្ជកម្មខ្លាំងចំពោះម៉ូដែលថ្មីនេះ។




**ពិធីសម្ពោធអគារតាំងបង្ហាញរថយន្តថ្មី**

កាលពីថ្ងៃទី១១ ខែមិថុនា ហ្វដ ខេមបូឌា បានបើកសម្ពោធអគារ 3S ថ្មីស្រឡាងរបស់ខ្លួនដែលមានបំណងផ្តល់ជូននូវផលិតផល ឬសេវាកម្ម ជាច្រើនដល់អតិថិជនរបស់ខ្លួន ដែលមាននៅក្នុងអាគារតែមួយ។



## ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក

វិស័យយានយន្តមិនប្រណិតនៅក្នុងប្រទេសកម្ពុជា បានបង្ហាញពីការស្ទុះងើបឡើងវិញគួរឱ្យការកត់សម្គាល់នៅត្រីមាសទី២ នៃឆ្នាំ២០២៤ ដែលសម្រេចបាននូវដំណើរការដូចគ្នាទៅនឹងត្រីមាសមុន ដែលលក់ចេញរថយន្តចំនួន ៦,៦០០ គ្រឿង។ បើប្រៀបធៀបទៅនឹងត្រីមាសទី២ នៃឆ្នាំ២០២៣ ទីផ្សាររថយន្តមិនប្រណិត គឺកើនឡើង +៧%។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់រយៈពេលប្រាំមួយខែដំបូងនៃឆ្នាំនេះ ទីផ្សារយានយន្តមិនប្រណិត នៅតែធ្លាក់ចុះ -១០% បើប្រៀបធៀបទៅនឹងរយៈពេលប្រហាក់ប្រហែលគ្នាកាលពីឆ្នាំមុន។

ក្នុងកំឡុងត្រីមាសទី២នេះ ការលក់របស់ RMAC បានធ្លាក់ចុះ -៩,៤% បើធៀបនឹងត្រីមាសដូចគ្នានៃឆ្នាំ២០២៣។ នៅក្នុងផ្នែកសំខាន់ៗរបស់យើង៖

**<u>ផ្សាររបស់រថយន្តម៉ាក Ford៖</u>**

រថយន្តម៉ាក Ford នៅតែរក្សាចំណាត់ថ្នាក់លេខមួយនៃរថយន្តដែលលក់ដាច់បំផុតនៅលើទីផ្សារនៃប្រទេសកម្ពុជា ក្នុងចំណោមទីផ្សាររថយន្តដែលមិនប្រណិត ជាមួយនឹងរថយន្តម៉ាក Ford Ranger ត្រូវបានជាប់ចំណាត់ថ្នាក់លេខមួយ ដែលលក់ដាច់បំផុតនៅលើទីផ្សារក្នុងប្រទេសកម្ពុជា។ យើងពិតជាមានមោទនភាពដែលរថយន្តដែលលក់បានភាគច្រើនត្រូវបានផលិតក្នុងប្រទេសកម្ពុជា។

**<u>គ្រឿងចក្រម៉ាក John Deere៖</u>** ដោយយោងតាមរបាយការណ៍ផ្ទៃក្នុងរបស់ក្រុមហ៊ុន គ្រឿងចក្រម៉ាក John Deere នៅជាអ្នកនាំមុខទី២ នៅក្នុងទីផ្សារត្រាក់ទ័រក្នុងប្រទេសកម្ពុជា និងរក្សាតំណែងជាអ្នកនាំមុខលើត្រាក់ទ័រធន់ធំ និងម៉ាស៊ីនប្រមូលផលនៅកម្ពុជា ហើយបានដណ្តើមយកចំណាត់ថ្នាក់ទីផ្សារវិញក្នុងកំឡុងឆ្នាំ ២០២៣។

**<u>លទ្ធផលហិរញ្ញវត្ថុ៖</u>**

ដោយសារការស្ទុះងើបឡើងវិញនៃទីផ្សាររបស់រថយន្ត ព្រមទាំងទិដ្ឋភាពវិជ្ជមាននៃវិស័យកសិកម្ម ក្រុមហ៊ុន RMAC ទទួលបានប្រាក់ចំណូលចំនួន ៨៤១,៣ ប៊ីលានរៀល ដែលមានការធ្លាក់ចុះ -៩,៤% បើប្រៀបធៀបនឹងឆ្នាំមុន។ សម្រាប់ជំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ ប្រាក់ចំណេញក្រោយបង់ពន្ធមានចំនួន ២០,៤ ប៊ីលានរៀល (ធ្លាក់ចុះ -៥៣,១% ធៀបនឹងត្រីមាសទី២ ឆ្នាំ២០២៣)។

លំហូរសាច់ប្រាក់សុទ្ធដែលប្រើប្រាស់លើការវិនិយោគនូវសាច់ប្រាក់មានចំនួន ១,២ ប៊ីលានរៀល ក្នុងត្រីមាសទី២ ឆ្នាំ២០២៤ ដោយរាប់បញ្ចូលការសាងសង់លើបន្ទប់តាំងបង្ហាញថ្មី និងការទិញរថយន្តម៉ាកថ្មីសម្រាប់ប្រតិបត្តិការ និងឧបករណ៍ប្រតិបត្តិការបន្ថែម។

## ខ. រចនាសម្ព័ន្ធប្រាក់ចំណូល

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនដែលមានលក្ខណៈបែបចម្រុះ ដែលបានតំណាងអោយយីហោលំដាប់ពិភពលោកមួយចំនួនរួមមាន Ford, Land Rover, Changan, After-Sales Mercedes-Benz, Fuso, John Deere, JCB និង Piaggio។ ផលចំណូលរបស់ក្រុមហ៊ុនទាំងអស់ ត្រូវបានបែងចែកជាពីរប្រភេទ៖

១. ការលក់ទំនិញ៖ ចំណូលទាក់ទងនឹងការលក់យានយន្ត និងឧបករណ៍ផ្សេងៗ។

២. ចំណូលពីសេវាកម្ម៖ ចំណូលទាក់ទងនឹងសេវាជួសជុល និងថែទាំយានយន្ត និងឧបករណ៍។

តារាងខាងក្រោមបង្ហាញពីចំណូលពីប្រភេទសម្រាប់ ត្រីមាសទី២ ឆ្នាំ២០២៤ និងរយៈពេលប្រៀបធៀបក្នុងកំឡុងពេលបីឆ្នាំចុងក្រោយ។

| គិតជាពាន់រៀល | ត្រីមាសទី២ ឆ្នាំ២០២៤ | ភាគរយ | ត្រីមាសទី២ ឆ្នាំ២០២៣ | ភាគរយ | ត្រីមាសទី២ ឆ្នាំ២០២២ | ភាគរយ |
|---|---|---|---|---|---|---|
| **ការលក់ទំនិញ** | ៤១៧.៥៣២.៨៧៩ | ៩៤,៦% | ៤៧១.១២៦.៥៩៨ | ៩៦,៧% | ៣០៦.២៨៦.២៤០ | ៩៥,២% |
| **ចំណូលនៃសេវាកម្ម** | ២៣.៧៩៣.០៤២ | ៥,៤% | ១៥.៩៤៤.០១៧ | ៣,៣% | ១៥.៤៩៣.៤៧៨ | ៤,៨% |
| **សរុប** | ៤៤១.៣២៥.៩២១ | ១០០,០% | ៤៨៧.០៧០.៦១៥ | ១០០,០% | ៣២១.៧៧៩.៧១៨ | ១០០,០% |

ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ

សូមយោងទៅលើឧបសម្ព័ន្ធស្តីពីព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នសម្រាប់បញ្ចប់ត្រីមាស គិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤។

## ផ្នែកទី៤. ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ១. ការវិភាគចំណូល

ចំណូលសរុប មានចំនួន ៤៩១,៣ ប៊ីលានរៀល ធ្លាក់ចុះចំនួន -៨៨៧,១ ប៊ីលានរៀល ឬ -៩,៤% ភាគរយ នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៤ បើធៀបនឹងត្រីមាសដូចគ្នាក្នុងឆ្នាំ២០២៣។

#### ២. ផ្នែកនៃចំណូល

ផ្នែករថយន្ត ហ្វដ (Ford) គ្រឿងចក្រធុនធ្ងន់ (Heavy-Equipment) និង ផ្នែក ម៉ូតូកង់បី (Piaggio) ទទួលបានកំណត់ត្រាអវិជ្ជមានយ៉ាងខ្លាំងនៃការធ្លាក់ចុះចំណូលនៅក្នុងត្រីមាស២ ឆ្នាំ២០២៤ បើធៀបទៅនឹងឆ្នាំមុន ខណៈពេលដែលរថយន្តម៉ាក Land Rover, Changan គ្រឿងចក្រកសិកម្ម (Agriculture) និងផលិតផលពិសេសរបស់ RMA ទទួលការកើនឡើងកំណត់ត្រាខ្លាំងជាងឆ្នាំមុន។

#### ៣. ការវិភាគអំពីប្រាក់ចំណេញមុនបង់ពន្ធ (PBT)

| គិតជាពាន់រៀល | ត្រីមាសទី២ ឆ្នាំ២០២៤ | ត្រីមាសទី២ ឆ្នាំ២០២៣ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ចំណូលសរុប | ៤៩១.៣២៥.៩២១ | ៨៨៧.០៧០.៦១៥ | (៩៥.៧៤៤.៦៩៤) | -៩,៤% |
| ចំណេញដុល | ៦២.០៥៦.០២៤ | ៨៩.០៥៨.៩៦៧ | (២៧.០០២.៩៤៣) | -៣០,៣% |
| គម្លាតចំណេញដុល | ១៤,១% | ១៨,៣% | | |
| ចំណាយ | ៣០.៧៤២.១៥៥ | ៣៣.១១៤.៩៨៣ | (២.៣៧២.៨២៨) | -៧,២% |
| ចំណាយហិរញ្ញវត្ថុ | ៥.៦០៣.៥៤៥ | ៦.៦៩៤.១៥៥ | (១.០៩០.៦១០) | -១៥,៧% |
| ប្រាក់ចំណេញមុនបង់ពន្ធ | ២៥.៧១០.៣២៤ | ៤៩.២៩៩.៨២៩ | (២៣.៥៨៩.៥០៥) | -៤៧,៨% |
| គម្លាត | ៥,៨% | ១០,១% | | |

#### ៤. ការវិភាគអំពីប្រាក់ចំណេញក្រោយបង់ពន្ធ (PAT)

| គិតជាពាន់រៀល | ត្រីមាសទី២ ឆ្នាំ២០២៤ | ត្រីមាសទី២ ឆ្នាំ ២០២៣ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ២៥.៧១០.៣២៤ | ៤៩.២៩៩.៨២៩ | (២៣.៥៨៩.៥០៥) | -៤៧,៨% |
| ចំណាយពន្ធ | ៥.២៧១.៨២១ | ៥.៦៩៦.៣៦១ | (៤២៤.៥៤០) | -៧,៥% |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | ២០.៤៣៨.៥០៣ | ៤៣.៦០៣.៤៦៨ | (២៣.១៦៤.៩៦៥) | -៥៣,១% |
| គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ | ៤,៦% | ៩,0% | | |

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ

### ១. ការវិភាគអំពីតម្រូវការ និង ការផ្គត់ផ្គង់

ជាទូទៅអតិថិជនរបស់ RMAC នៅក្នុងប្រទេសកម្ពុជាបានបង្ហាញពីចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការទិញផលិតផលសំខាន់ៗរបស់ RMAC ដែលមានដូច ជា Ford, Changan, John Deere និង Land Rover ។

បច្ចុប្បន្ន RMAC កំពុងតាមដានយ៉ាងជិតដល់នូវការនាំចូល និងប្រភពធនធាននៃផលិតផលសម្រាប់ផ្នែកនីមួយៗ ដើម្បីធ្វើការសម្រេចចិត្តសមស្របតាមលក្ខខណ្ឌនៃការបញ្ជាទិញផលិតផល។

### ២. ការវិភាគអំពីការប្រែប្រួលនូវតម្លៃវត្ថុធាតុដើម

មិនមានការប្រែប្រួលសំខាន់លើតម្លៃនៃវត្ថុធាតុដើមឡើយ។

### ៣. ការវិភាគអំពីពន្ធដារ

មិនមានការប្រែប្រួលលើលិខិតបទដ្ឋានគតិយុត្តិផ្នែកពន្ធដារក្នុងប្រទេសកម្ពុជាណាមួយ ដែលនាំអោយមានផលប៉ះពាល់សំខាន់ណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

### ៤. ការវិភាគអំពីទំនិញលើកលែង និងទំនិញពិសេស

មិនមានទំនិញលើកលែង និងទំនិញពិសេសក្នុងអំឡុងពេលនេះឡើយ។

## គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល

ចំណូលសម្រាប់ត្រីមាសទី២ ឆ្នាំ២០២៤ ប្រៀបធៀបរយៈពេលដូចគ្នានាឆ្នាំ ២០២៣ ដែលត្រូវបានបង្ហាញក្នុងឯកសារនេះ និងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេប។

## ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ

ការប្រែប្រួលអត្រាប្តូរប្រាក់ មិនមានការប៉ះពាល់ចំបងណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ ដោយហេតុថាអាជីវកម្មមួយចំនួនធំរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់រៀល/ប្រាក់ដុល្លារអាមេរិក ដោយភ្ជាប់ជាមួយនឹងការបញ្ជាទិញនូវផលិតផលនាំចូលតិចតួចប៉ុណ្ណោះដែលធ្វើឡើងជារូបិយបណ្ណបរទេស។ ក្រុមហ៊ុន មិនបានទទួលរងផលប៉ះពាល់ដោយតម្លៃទំនិញ ដោយសារក្រុមហ៊ុនមិនបានធ្វើការដោះដូរទំនិញឡើយ។ អត្រាការប្រាក់ មានការប្រែប្រួលបន្តិចបន្តួចតែប៉ុណ្ណោះក្នុងអំឡុងពេលនេះ។

## ង. ផលប៉ះពាល់នៃអតិផរណា

មិនមានផលប៉ះពាល់ចំបងណាមួយនៃអតិផរណា ដែលបានប៉ះពាល់ដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

នាពេលថ្មីៗនេះ យើងមិនត្រូវទទួលបានការជូនដំណឹងអំពីគោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ ឬ រូបិយវត្ថុដែលអាចមានផលប៉ះពាល់ដល់អាជីវកម្មរបស់ RMAC តាមរបៀបណាមួយឡើយ។

## ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ

មិនមានព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសនេះទេ។

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ

កាលបរិច្ឆេទ៖ ២៨ សីហា ២០២៤

បានឯកភាព និង អនុម័ត

ឈ្មោះ Kevin Whitcraft

តួនាទី៖ ប្រធានក្រុមប្រឹក្សាភិបាល

បានឯកភាព និង អនុម័ត

ឈ្មោះ ងន សាំង

តួនាទី៖ នាយកប្រតិបត្តិ

